**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៤៩..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមលេខាធិការនៃក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសម្រេច លេខ ២៩ សសរ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតក្រុមលេខាធិការ នៃក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **រាជ សុគន្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២. | លោកជំទាវ | **ឡាយ អូនរី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៣. | លោក | **ម៉ុត ជិ** | សមាជិកក្រុមប្រឹក្សានីតិកម្ម និងជាមន្ត្រី ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាអនុប្រធានប្រចាំការ |
| ៤. | លោក | **កែម គុជសី** | អនុប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងមហាផ្ទៃ | ជាសមាជិក |

| | | | |
|---|---|---|---|
| ៥. | លោក **ទៀម សារី** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល រាជធានី ខណ្ឌ និងខេត្ត ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦. | លោក **ឡាយ ម៉ុណ្ណារិទ្ធ** | ជំនួយការ **ឯកឧត្តម ខឹ ចំរ៉ុន្ធផល** រដ្ឋលេខាធិការ និងជា អនុប្រធាននាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៧. | លោក **ស៊ុន ឈុនហៀង** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល រាជធានី ខណ្ឌ និងខេត្ត ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៨. | លោក **សាលី ដារ៉ា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៩. | លោក **ម៉ុត សុបាន** | ជំនួយការ **ឯកឧត្តម ខឹ ចំរ៉ុន្ធផល** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១០. | លោក **ម៉ុល មីនា** | ជំនួយការ **ឯកឧត្តម លេខ ទី** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១១. | លោក **សាយ សុតត្ថ្រា** | ប្រធានការិយាល័យ នាយកដ្ឋានកិច្ចការរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១២. | លោក **យឹម ម៉ាន់នី** | អនុប្រធានការិយាល័យ នាយកដ្ឋានបុគ្គលិក ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៣. | កញ្ញា **ឱ កញ្ញារតនៈ** | អនុប្រធានការិយាល័យទំនាក់ទំនងអន្តរវិស័យលេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៤. | លោក **ស៊ុយ សែនសីហៈ** | មន្ត្រី នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៥. | លោក **ចិន្តា តក្កី** | មន្ត្រី នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៦. | លោក **ស៊ឹម ឡឿន** | មន្ត្រីអង្គភាពការពារ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៧. | លោក **អ៊ុន សារឿន** | មន្ត្រី នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៨. | លោក **ពេញ ពន្លក** | មន្ត្រី នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាសមាជិក |

**ប្រការ ២.–**

ក្រុមលេខាធិការ ជាសេនាធិការឲ្យក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន និងមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ទទួលរបាយការណ៍ពីក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន រាជធានី ខេត្ត ដើម្បីបូកសរុបធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដាក់ជូនក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីពិនិត្យ និងសម្រេច
- បូកសរុប វាយតម្លៃអំពីបញ្ហាប្រឈមផ្សេងៗ ក្នុងសកម្មភាពការងារចុះមូលដ្ឋានរបស់ក្រុមការងារថ្នាក់ជាតិ
- រៀបចំកិច្ចប្រជុំ របៀបវារៈជាទៀងទាត់តាមការកំណត់
- រៀបចំគ្រប់គ្រង លិខិតស្នាមរដ្ឋបាល សេចក្តីសម្រេច និងឯកសារនានារបស់ក្រុមការងារថ្នាក់ជាតិ
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីឯកឧត្តមប្រធានក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន។

**ប្រការ ៣.-**

ក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ២ ប្រធានក្រុមលេខាធិការ ត្រូវសុំយោបល់ជាប្រចាំពីប្រធានក្រុមជំនួយការ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន។ ប្រធានក្រុមលេខាធិការ មានសិទ្ធិចាត់ចែង ប្រគល់ភារកិច្ចដល់អនុប្រធាន និងសមាជិកក្រុមការងារព្រមទាំងកោះប្រជុំតាមការចាំបាច់។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ អស់លោក ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៥*

**ត.ប នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

<u>**កន្លែងទទួល**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- សាមីខ្លួនដូចមានចែងក្នុងប្រការ ១
- *ឯកសារ-កាលប្បវត្តិ*